**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ២០៦៩ ភក.ភវ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារតាមដានប្រព័ន្ធទំនាក់ទំនងបណ្ដាញសង្គម Facebook
## របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសេចក្ដីណែនាំរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦

### សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារតាមដានប្រព័ន្ធទំនាក់ទំនងបណ្ដាញសង្គមFacebook ( https://www.facebook.com/hunsencambodia ) របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហ៊ុយ វណ្ណៈ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **គៀត ច័ន្ទថារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ម៉ៅ ឥទ្ធិ** | អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤-លោកជំទាវ | **តៅ សុខម៉ារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៥-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ហួន ច័ន្ទកក្កដា** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៦-ឯកឧត្តមឧត្តមអគ្គានុរក្សថ្នាក់លេខ១ | **នុត សមនា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ | សមាជិក |
| ៧-ឯកឧត្តមឧត្តមសេនីយ៍ឯក | **កែវ វណ្ណថន** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ | សមាជិក |
| ៨-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ចាន់ គីមសេង** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម | សមាជិក |
| ៩-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ឯក មនោសែន** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល | សមាជិក |
| ១០-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ម៉ាង រ៉ាស៊ី** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម | សមាជិក |
| ១១-ឯកឧត្តមឧត្តមសេនីយ៍ទោ | **ម៉ែន សុរិយន់** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន សវនកម្មផ្ទៃក្នុង | សមាជិក |
| ១២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ចេន ចាន់តុង** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំ | សមាជិក |

**ប្រការ២:** ក្រុមការងារតាមដានប្រព័ន្ធទំនាក់ទំនងបណ្តាញសង្គម Facebook របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានតួនាទី ភារកិច្ចតាមដាន និងឆ្លើយតបតាមជំនាញនីមួយៗស្របតាមគោលការណ៍របស់ក្រសួងមហាផ្ទៃចំពោះមតិមហាជន ដែលបង្ហោះនៅក្នុងទំព័រហ្វេសប៊ុករបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ពាក់ព័ន្ធនឹងវិស័យសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

**ប្រការ៣:** អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គាធិការដ្ឋាន បណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកដ្ឋានពន្ធនាគារ ក្រុមប្រឹក្សានីតិកម្ម និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្រប់ប្រធាននាយកដ្ឋាន ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងសាមីខ្លួនមានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន:</u>

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
(ដើម្បីជូនជ្រាប)
-ដូចប្រការ១ និងប្រការ៣
(ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ